រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ៥៥០ ចសណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ជំរាបមក**

**ឯកឧត្តម អភិបាលរាជធានីភ្នំពេញ និងអភិបាលគ្រប់ខេត្ត**

**កម្មវត្ថុ** : ស្តីពីការរៀបចំផ្ទេរសិទ្ធិរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស ដើម្បីទៅឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**យោង** : ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបមកឯកឧត្តមថា : កន្លងមកក្រសួងមហាផ្ទៃបានពិនិត្យឃើញថា មានមន្ត្រីរាជការមួយចំនួនដែលស្ថិតក្នុងមុខតំណែងអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ បានដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស ដើម្បីទៅឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៩ខាងមុខ រហូតដល់ថ្ងៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រកាសលទ្ធផលជាផ្លូវការ ។

ដើម្បីធានានិរន្តរភាពការងាររដ្ឋបាល និងការដឹកនាំគ្រប់គ្រងនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

១-ចំពោះអភិបាលរាជធានី និង អភិបាលខេត្ត ដែលបានដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស ដូចបានរៀបរាប់ខាងលើ ក្រសួងនឹងធ្វើការតែងតាំង ឬប្រគល់ភារកិច្ចជូនអភិបាលរងម្នាក់ពីក្នុងចំណោម អភិបាលរងរាជធានី និងខេត្ត ឱ្យទទួលសិទ្ធិដឹកនាំបន្តជាអភិបាលស្តីទី ។ អភិបាលស្តីទីត្រូវទទួលខុសត្រូវដឹកនាំការងារ រហូតដល់មានអភិបាលរាជធានី ឬអភិបាលខេត្តថ្មីមកជំនួស ។

២-ចំពោះអភិបាលក្រុង ស្រុក ខណ្ឌ ដែលបានដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស ដើម្បីទៅឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ក្រសួងប្រគល់ភារកិច្ចជូនឯកឧត្តមអភិបាល ឬអភិបាលស្តីទី នៃសាលារាជធានី និងសាលាខេត្ត ជ្រើសរើសអភិបាលរងក្រុង ស្រុក ខណ្ឌមួយរូប និងចេញ **ដីកា** ប្រគល់ភារកិច្ចបណ្តោះអាសន្នជូនអភិបាលរងរូបនោះ ឱ្យទទួលជាអភិបាលស្តីទី នៃសាលាក្រុង សាលាស្រុក និងសាលាខណ្ឌ ។ អភិបាលស្តីទីត្រូវទទួលខុសត្រូវដឹកនាំការងារ ឬរហូតដល់មានអភិបាលក្រុង ស្រុក ខណ្ឌថ្មីមកជំនួស ។

ផ្អែកតាមការណែនាំនេះ ក្រសួងមានសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តមអភិបាលរាជធានី និង ឯកឧត្តមអភិបាលគ្រប់ខេត្ត នឹងយកចិត្តទុកដាក់ចាត់ចែងអនុវត្ត ដោយស្មារតីទទួលខុសត្រូវខ្ពស់ និង ទាន់ពេលវេលា ។

សូមឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ.

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

  *( ដើម្បីជូនជ្រាបជាព័ត៌មាន )*
- ឯកសារ - កាលប្បវត្តិ